# កំណត់ហេតុកិច្ចប្រជុំ

## ព្រមព្រៀងលើវិសោធនកម្មលើកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយម វៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់ការជួញដូរស្ត្រី និង កុមារ និងជួយដល់ជនរងគ្រោះដោយសារការជួញដូរ

(ទីក្រុងហូជីមីញ ប្រទេសវៀតណាម, ថ្ងៃទី ២៧-២៨ ខែ កញ្ញា ឆ្នាំ ២០១២)

ដោយមានការយល់ព្រមពីរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម គណៈប្រតិភូតំណាងមន្ត្រីជាន់ខ្ពស់អន្តរក្រសួងនៃព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម បានរៀបចំកិច្ចប្រជុំពិភាក្សាយល់ព្រម កែសម្រួល និងបំពេញបន្ថែមលើកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់ការជួញដូរស្ត្រី និងកុមារ និងជួយដល់ជនរងគ្រោះដោយសារការជួញដូរ ទីក្រុងហូជីមិញ នាថ្ងៃទី២៧-២៨ ខែកញ្ញា ឆ្នាំ២០១២។

គណៈប្រតិភូតំណាងមន្ត្រីជាន់ខ្ពស់អន្តរក្រសួងនៃប្រទេសវៀតណាមរួមមានៈ តំណាងក្រសួងសន្តិសុខសាធារណៈ តំណាងខុទ្ទកាល័យរដ្ឋាភិបាល ក្រសួងការងារ យុទ្ធជនពិការ និងសង្គមកិច្ច ក្រសួងយុត្តិធម៌ ក្រសួងការបរទេស សមាគមនារីមជ្ឈិមវៀតណាម គណៈបញ្ជាការយោធាការពារព្រំដែន ក្រសួងព័ត៌មាន និងទូរគមនាគមន៍ តំណាងនគរបាលនៃបណ្តាខេត្តទាំង៦ ជាប់ព្រំដែនកម្ពុជា និងទីក្រុងហូជីមិញ ដឹកនាំដោយលោកឧត្តមសេនីយ៍ត្រី Do Kim Tuyen អគ្គស្នងការរងនៃអគ្គនាយកដ្ឋាននគរបាលបង្ការ និងប្រឆាំង បទល្មើសនៃក្រសួងសន្តិសុខសាធារណៈ ជាប្រធានគណៈប្រតិភូ។

គណៈប្រតិភូតំណាងមន្ត្រីជាន់ខ្ពស់អន្តរក្រសួងនៃប្រទេសកម្ពុជារួមមានៈ ក្រសួងកិច្ចការនារី ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មហាអយ្យការអមសាលាឧទ្ធរណ៍ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស និងអាជ្ញាធរខេត្តស្វាយរៀង ដឹកនាំដោយលោកជំទាវ សាន្ត អារុណ រដ្ឋលេខាធិការក្រសួងកិច្ចការនារី ជាប្រធានគណៈប្រតិភូ។

ចូលរួមកិច្ចប្រជុំនេះ ក៏មានតំណាងអង្គការអន្តរជាតិមួយចំនួន ដូចជា៖ UNIAP, UNICEF, IOM, UNODC និងអង្គការទស្សនៈពិភពលោកប្រចាំប្រទេសវៀតណាម និងកម្ពុជា (បញ្ជីឈ្មោះនៃគណៈប្រតិភូទាំងពីរមានភ្ជាប់ជូនក្នុងឧបសម្ព័ន្ធ ១ និង ២ នៃកំណត់ហេតុនេះ)។

បន្ទាប់ពីសុន្ទរកថាបើកកិច្ចប្រជុំរបស់ប្រធានគណៈប្រតិភូវៀតណាម និងសុន្ទរកថារបស់ប្រធានគណៈប្រតិភូកម្ពុជា ប្រធានគណៈប្រតិភូទាំងពីរបានឯកភាពទៅលើកម្មវិធីនៃកិច្ចប្រជុំដែលមានខ្លឹមសារសំខាន់ៗចំនួនបីគឺ៖ ទីមួយ ការវាយតម្លៃលទ្ធផលនៃកិច្ចសហប្រតិបត្តិការអនុវត្តកិច្ចព្រមព្រៀងនៅក្នុងឆ្នាំ ២០១១ និង ៦ ខែ ដើមឆ្នាំ ២០១២, ទីពីរ ការពិភាក្សាពិនិត្យឡើងវិញនូវខ្លឹមសារកែសម្រួល និងបំពេញបន្ថែមលើកិច្ចព្រមព្រៀង, និងទីបី ការពិភាក្សាឯកភាពទៅលើផែនការសកម្មភាពរួមសម្រាប់អនុវត្តកិច្ចព្រមព្រៀងក្នុងឆ្នាំ ២០១៣-២០១៥។

គណៈប្រតិភូបានវាយតម្លៃលទ្ធផលសហប្រតិបត្តិការអនុវត្តកិច្ចព្រមព្រៀងឆ្នាំ ២០១១ និង ៦ ខែដើមឆ្នាំ ២០១២ និងសមិទ្ធផលដែលប្រទេសទាំងពីរសម្រេចបានក្នុងការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងបានសង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងប្រទេសទាំងពីរ។

ផ្អែកលើលទ្ធផលនៃកិច្ចប្រជុំពិនិត្យឡើងវិញ កែសម្រួល និងបំពេញបន្ថែមលើកិច្ចព្រមព្រៀងដែលបានរៀបចំនៅខេត្តសៀមរាប ប្រទេសកម្ពុជា គណៈប្រតិភូនៃប្រទេសទាំងពីរបានពិភាក្សាពិនិត្យឡើងវិញ និងព្រមព្រៀងកែសម្រួល និងបំពេញបន្ថែមលើកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់ការជួញដូរស្ត្រី និងកុមារ និងជួយដល់ជនរងគ្រោះដោយសារការជួញដូរ។ គណៈប្រតិភូទាំងពីរក៏បានពិភាក្សាលើផែនការសកម្មភាពរួមសម្រាប់អនុវត្តកិច្ចព្រមព្រៀងក្នុងរយៈពេល ២០១៣-២០១៥។

បន្ទាប់ពីពិភាក្សា និងផ្លាស់ប្តូរយោបល់ ភាគីទាំងពីរបានឯកភាព៖

១- ខ្លឹមសារកែសម្រួល និងបំពេញបន្ថែមលើកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខានៅថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០០៥។ ខ្លឹមសារទាំងនោះមាន៤ចំណុច៖

ក).-កែសម្រួលចំណងជើងរបស់កិច្ចព្រមព្រៀង

ខ).-កែសម្រួល លុបចេញ និងបំពេញបន្ថែមខ្លឹមសារចំនួន១១ ដែលពាក់ព័ន្ធទៅនឹងមាត្រា នៃកិច្ចព្រមព្រៀង

គ).កែសម្រួលបច្ចេកទេសទៅលើវាក្យសព្ទមួយចំនួនក្នុងកិច្ចព្រមព្រៀង

ឃ).កំណត់អំពីការចូលជាធរមាននៃកិច្ចព្រមព្រៀងវិសោធនកម្ម បន្ទាប់ពីទទួលបានការជូនដំណឹងជាលាយលក្ខណ៍អក្សរ ដែលបញ្ជាក់អំពីការយល់ព្រមរបស់រដ្ឋាភិបាលទាំងពីរ។

ប្រធានគណៈប្រតិភូទាំងពីរបានចុះហត្ថលេខាសង្ខេបលើអត្ថបទនៃកិច្ចព្រមព្រៀងវិសោធនកម្ម ដើម្បីដាក់ជូនរដ្ឋមន្ត្រីទាំងពីររូបចុះហត្ថលេខានៅរសៀល ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ ២០១២។

២.លើខ្លឹមសារផែនការសកម្មភាពរួមសម្រាប់អនុវត្តកិច្ចព្រមព្រៀងក្នុងរយៈពេល ២០១៣-២០១៥ (មានភ្ជាប់ជូនក្នុងឧបសម្ព័ន្ធ ៣)។ ខ្លឹមសារនៃការងារនេះបានកំណត់បែងចែកសមត្ថកិច្ចទទួលបន្ទុក នៃស្ថាប័នពាក់ព័ន្ធរបស់ប្រទេសទាំងពីរដើម្បីចាត់តាំងអនុវត្ត។

៣. យល់ព្រមលើខ្លឹមសារវាយតម្លៃលទ្ធផលសហប្រតិបត្តិការអនុវត្តកិច្ចព្រមព្រៀងនៅក្នុងឆ្នាំ ២០១១ និង៦ខែដើមឆ្នាំ ២០១២។

កំណត់ហេតុនេះ ត្រូវបានធ្វើជាពីរច្បាប់ ជាភាសាខ្មែរ និងភាសាវៀតណាម ហើយអត្ថបទទាំងពីរមានតម្លៃស្មើគ្នា៕

ប្រធានគណៈប្រតិភូកម្ពុជា

**លោកជំទាវ សាន្ត អារុណ**

**រដ្ឋលេខាធិការ**

**ក្រសួងកិច្ចការនារី និងជា**

**ប្រធានក្រុមការងារ** COMMIT **កម្ពុជា**

ប្រធានគណៈប្រតិភូវៀតណាម

**ឧត្តមសេនីយ៍ត្រី** Do Kim Tuyen

**អគ្គស្នងការរងនគរបាលបង្ការនិងប្រឆាំងបទល្មើស**

**ក្រសួងសន្តិសុខសាធារណៈ និងជា**

**អនុប្រធានគណៈកម្មការអន្តរក្រសួង**

COMMIT **វៀតណាម**